**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

លេខ : ៥៥៧/២៤ មស.សារណ

ថ្ងៃ អង្គារ ១១កើត ខែ មាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៤

# សេចក្តីជូនដំណឹង

**គណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការ ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងសាធារណការ និងដឹកជញ្ជូន** សូមជូនដំណឹងដល់បេក្ខជន ដែលបានដាក់ពាក្យចូលរួមការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងសាធារណការ និងដឹកជញ្ជូន ឆ្នាំ២០២៣ ឱ្យបានជ្រាបថា បេក្ខជនទាំងអស់ ត្រូវចូលរួមការប្រឡង ដែលនឹងប្រព្រឹត្តទៅដូចខាងក្រោម៖

ក-សម័យប្រឡង និងមណ្ឌលប្រឡង

-សម័យប្រឡងថ្ងៃចន្ទ ទី៤ ខែមីនា ឆ្នាំ២០២៤

-មណ្ឌលប្រឡង សាលាភូមិន្ទរដ្ឋបាល (ទីតាំងស្ថិតតាមបណ្តោយវិថីឧកញ៉ាញឹកជូឡុង សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ)

ខ-វិញ្ញាសាប្រឡង

- វិញ្ញាសាចំណេះដឹងទូទៅ (សំណួរពហុចម្លើយពាក់ព័ន្ធនឹងរដ្ឋបាល មុខងារសាធារណៈ ក្រមសីលធម៌, វប្បធម៌ទូទៅ, ព័ត៌មានវិទ្យា) "រយៈពេល ១ម៉ោង" (ម៉ោង១២៖៣០នាទី ដល់ម៉ោង ១៣៖៣០នាទី) មេគុណ១
- វិញ្ញាសាជំនាញ "រយៈពេល ២ម៉ោង" (ម៉ោង១៤៖០០នាទី ដល់ម៉ោង ១៦៖០០នាទី) មេគុណ៣
- វិញ្ញាសាភាសាអង់គ្លេស "រយៈពេល១ម៉ោង"( ម៉ោង១៦៖៣០នាទីដល់ម៉ោង១៧៖៣០នាទី ) មេគុណ១។

**<u>បញ្ជាក់៖</u>**

+បេក្ខជនត្រូវមកដល់មណ្ឌលប្រឡង ១ម៉ោងមុនការប្រឡង(ម៉ោង១១៖៣០នាទី) និងភ្ជាប់មកជាមួយនូវ៖

១-សលាកបត្រឯកត្តជន និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬឆាយា(ព្រះសង្ឃ) ឬលិខិតបញ្ជាក់អត្តសញ្ញាណផ្សេងទៀត ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច។

២-ប៊ិចពណ៌ខៀវ និងបន្ទាត់ សម្រាប់ប្រើប្រាស់ពេលប្រឡង។

+បេក្ខជនមិនត្រូវយកឯកសារផ្សេងៗ ព្រមទាំងឧបករណ៍អេឡិចត្រូនិកគ្រប់ប្រភេទ (កុំព្យូទ័រ, ទូរស័ព្ទ, នាឡិកាឆ្លាតវៃ...) ចូលក្នុងមណ្ឌលប្រឡងជាដាច់ខាត និងមិនមានការទទួលរក្សាទុកនោះទេ។

+សម្លៀកបំពាក់សមរម្យ៖

- សម្រាប់ស្ត្រី ៖ សំពត់ពណ៌ខ្មៅ ឬពណ៌ទឹកប៊ិចចាស់ក្រោមជង្គង់ និងអាវពណ៌ស
- សម្រាប់បុរស ៖ ខោជើងវែងពណ៌ខ្មៅ ឬពណ៌ទឹកប៊ិចចាស់ និងអាវពណ៌ស។

ចំពោះការបែងចែកលេខបន្ទប់ លេខតុ និងព័ត៌មានផ្សេងៗ ពាក់ព័ន្ធដំណើរការនៃការប្រឡង នឹងត្រូវប្រកាសផ្សព្វផ្សាយនៅពេលក្រោយ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមបេក្ខជនទាំងអស់ ជ្រាបជាព័ត៌មាន និងអនុវត្តឱ្យបានម៉ឺងម៉ាត់។

**គណៈកម្មការរៀបចំការប្រឡងប្រជែង**

ផ្លូវវិថីអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh